ក្រសួងមហាផ្ទៃ
Ministry of Interior

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

# លក្ខខណ្ឌតម្រូវជាមូលដ្ឋានមួយចំនួន នៃនីតិវិធីរៀបចំការធ្វើបាតុកម្មស្របតាមច្បាប់ ស្តីពីបាតុកម្ម ដោយសន្តិវិធី និងគោលការណ៍ណែនាំសម្រាប់អនុវត្តច្បាប់នេះ។

## ១). ការប្រមូលផ្តុំដែលមិនចាំបាច់តម្រូវឲ្យមានលិខិតជូនដំណឹង

ការប្រមូលផ្តុំដែលមិនចាំបាច់តម្រូវឲ្យមានលិខិតជូនដំណឹងជាលាយលក្ខអក្សរទៅកាន់អាជ្ញាធរ

ការប្រមូលផ្តុំ មិនទាក់ទងទៅនឹងការទាមទារជាសាធារណៈណាមួយដូចជា ៖

- ជួបជុំគ្នា ក្នុងគោលបំណងដទៃផ្សេងក្រៅពីការតវ៉ាទាមទារជាសាធារណៈ
- ការជួបប្រជុំ ដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយបញ្ហាជាក់លាក់ណាមួយ
- សកម្មភាពផ្សព្វផ្សាយអប់រំផ្សេងៗ ដូចជា ៖
  - ការបណ្តុះបណ្តាល
  - សិក្ខាសាលា
  - វេទិកាសាធារណៈ
  - សន្និសីទសារព័ត៌មាន ។ល។
- ការធ្វើព្យុហយាត្រា ឬពិធីដង្ហែសព
- ការជួបប្រជុំអំឡុងពេលយុទ្ធនាការបោះឆ្នោត
- ឬការធ្វើកិច្ចការសាសនា សិល្បៈ វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់ជាតិ

## ២). កាតព្វកិច្ចរបស់អ្នករៀបចំ

ប្រសិនបើអ្នករៀបចំធ្វើការប្រមូលផ្តុំនៅទីលានសាធារណៈណាមួយ ឬការដើរដង្ហែជាក្បួននៅតាមផ្លូវសាធារណៈ ដើម្បីទាមទារអ្វីមួយ

អ្នកត្រូវដាក់លិខិតជូនដំណឹងជាលាយលក្ខអក្សរនៅសាលារាជធានីភ្នំពេញ ឬនៅសាលាខេត្ត ដោយបញ្ជាក់អំពី ៖

- នាម និងគោត្តនាមរបស់អ្នកដឹកនាំ ៣ រូប
- អាស័យដ្ឋានរបស់អ្នកដឹកនាំ ៣ រូប
- អត្តសញ្ញាណប័ណ្ណថតចម្លងរបស់អ្នកដឹកនាំ ៣ រូប
- គោលបំណងនៃការធ្វើបាតុកម្មនោះ
- កាលបរិច្ឆេទ ពេលវេលា និងរយៈពេលធ្វើបាតុកម្ម
- ទីតាំង និងវិថី/ផ្លូវដែលត្រូវប្រើប្រាស់សម្រាប់ធ្វើបាតុកម្ម
- ចំនួនអ្នកចូលរួម និង
- ចំនួនយានជំនិះតាមប្រភេទនីមួយៗ

ពេលត្រូវដាក់លិខិត ៖ យ៉ាងហោចណាស់ ៥ថ្ងៃ នៃថ្ងៃធ្វើការ មុននឹងធ្វើការប្រមូលផ្តុំ ឬការដើរដង្ហែក្បួន

ប្រសិនបើអ្នករៀបចំធ្វើការប្រមូលផ្តុំនៅកន្លែងបញ្ចេញមតិសាធារណៈឬនៅទីតាំងឯកជនឬនៅទីតាំងសមូហភាពណាមួយ ដើម្បីធ្វើការទាមទារអ្វីមួយ

អ្នកត្រូវដាក់លិខិតជូនដំណឹងជាលាយលក្ខអក្សរ ដោយបញ្ជាក់អំពី ៖

- នាម និងគោត្តនាមរបស់អ្នកដឹកនាំ ៣ រូប
- អត្តសញ្ញាណប័ណ្ណថតចម្លងរបស់អ្នកដឹកនាំទាំង ៣ រូប នោះ
- ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដឹកនាំ ៣ រូប
- ចំពោះទីតាំងឯកជន ឬទីតាំងសមូហភាព ត្រូវមានការយល់ព្រមពីម្ចាស់ទ្រព្យ ឬពីគណៈគ្រប់គ្រងទ្រព្យ

ពេលត្រូវដាក់លិខិត ៖ យ៉ាងតិច ១២ ម៉ោងជាមុន ក្នុងថ្ងៃធ្វើការ ឬ ៣៦ ម៉ោងជាមុន ក្នុងថ្ងៃឈប់សម្រាកជាសាធារណៈ

លិខិតជូនដំណឹងជាលាយលក្ខអក្សរត្រូវដាក់នៅសាលារាជធានី ឬសាលាខេត្ត

### ៣). កាតព្វកិច្ចរបស់អាជ្ញាធររាជធានី ឬខេត្ត

## នៅពេលទទួលលិខិតជូនដំណឹងអាជ្ញាធររាជធានី ឬខេត្តត្រូវ៖

- ចេញបង្កាន់ដៃទទួលស្គាល់ជាលាយលក្ខអក្សរជូនអ្នកដែលបានដាក់លិខិតជូនដំណឹង
- ផ្សព្វផ្សាយលិខិតជូនដំណឹងនោះជាបន្ទាន់នៅទីកន្លែងណាមួយដែលងាយមើលឃើញក្នុងអាគាររដ្ឋបាល ឬនៅលើគេហទំព័រផ្លូវការរបស់ខ្លួន
- បញ្ជូនច្បាប់ចតចម្លងនៃលិខិតជូនដំណឹងនេះ ទៅកាន់ស្នាក់ការនគរបាលមូលដ្ឋាន ស្នាក់ការកងរាជអាវុធហត្ថ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត។

**ឆ្លើយតប ជាវិជ្ជមាន លើកលែងតែ ៖**

- បាតុកម្មត្រូវចំលើថ្ងៃប្រារព្ធពិធីបុណ្យធំៗ ដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី

មានព័ត៌មានច្បាស់ថា ៖ បាតុកម្មអាចបង្កឲ្យមានគ្រោះថ្នាក់ឬអាចបង្កឲ្យអន្តរាយដល់សន្តិសុខ សុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ។ អាជ្ញាធររាជធានី ឬខេត្តត្រូវពិចារណាឲ្យបានហ្មត់ចត់ផងថា ៖

- *បាតុកម្មតវ៉ាមិនមែនសុទ្ធតែជា "ការបង្កគ្រោះថ្នាក់ ឬប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ" ទេ។*
- *ការកកស្ទះចរាចរណ៍មិនមែនសុទ្ធតែជាការ " បង្កគ្រោះថ្នាក់ ឬប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ " ទេ។*

- អាជ្ញាធររាជធានី ឬខេត្តត្រូវអញ្ជើញ អ្នកជូនដំណឹងមកពិភាក្សារកដំណោះស្រាយជាមួយគ្នា
- អាជ្ញាធររាជធានី ឬខេត្តត្រូវស្នើសុំយោបល់សម្រេចពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវឆ្លើយតបជាលាយលក្ខអក្សររយៈពេល ២៤ម៉ោង មុនពេលកំណត់ធ្វើបាតុកម្ម

**ធ្វើការឆ្លើយតបក្នុងកំឡុងពេល ៣ ថ្ងៃ នៃថ្ងៃធ្វើការ**

ការមិនបានឆ្លើយតបពីអាជ្ញាធរ មានន័យថាអាជ្ញាធរបានយល់ព្រម ហើយការធ្វើបាតុកម្មអាចប្រព្រឹត្តទៅបាន ដោយមិនមានការបំបែក ឬការរារាំងឡើយ។

ក្រសួងមហាផ្ទៃ
Ministry of Interior

អង្គការសហប្រជាជាតិ សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ កម្ពុជា

## ព្រឹត្តបត្រព័ត៌មាន

## លក្ខខណ្ឌតម្រូវជាមូលដ្ឋានមួយចំនួននៃនីតិវិធីរៀបចំការធ្វើបាតុកម្មស្របតាមច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី និងគោលការណ៍ណែនាំសម្រាប់អនុវត្តច្បាប់នេះ។